

សុធា កំពុងប្រមូលឥដ្ឋ ដែលទើបតែរៀបពុម្ពរួច

# ការចាកចេញពីឡឥដ្ឋ៖ ពលករកុមារម្នាក់បន្តព្យាយាមដើម្បីការសិក្សាសម្រាប់អនាគតដ៏ល្អរបស់ខ្លួន

ថា សុធា ដែលមានរាងកាយខ្ពស់ និងសុភាពរាបសារ បាននិយាយអំពីស្ថានភាពមួយចំនួន នៃភាពក្លាហាននៅក្នុងជីវិត ហើយនឹងការអប់រំរបស់គាត់។ សុធា បានចំណាយពេលស្ទើរពេញ ១៦ឆ្នាំ រស់នៅ និងធ្វើការនៅក្នុងឡឥដ្ឋ ដែលមានទីតាំងនៅឃុំបាក់ខែង។ ក្រៅពីពេលសិក្សា សុធា បានជួយឪពុកម្តាយធ្វើការនៅក្នុងឡឥដ្ឋ ដោយជួយបន្ថែមអុសដាក់ទៅក្នុងឡដុតឥដ្ឋ។

សុធា និយាយថា៖ "គ្រួសាររបស់ខ្ញុំធ្វើការពេញម៉ោងទាំងយប់ទាំងថ្ងៃ"។ សុធា បន្ត៖ "ពួកគាត់មិនអាចសម្រាកបានទេ ព្រោះបើយើងមិនតាមដានទេ អូសមិនអាចឆេះល្អដើម្បីដុតឥដ្ឋអោយឆ្អិនល្អបានទេ"។

សុធានិយាយថា ឪពុកម្តាយរបស់សុធាទទួលបានប្រាក់ឈ្នួល ៥០០,០០០ រៀល (១២៥ ដុល្លារសហរដ្ឋអាមេរិច) ពីម្ចាស់ឡឥដ្ឋ សម្រាប់ការដុតឥដ្ឋឆ្អិនរួចរាល់មួយឡរាល់លើក។ ក្នុងមួយឡសម្រាប់ការដុតឥដ្ឋអោយឆ្អិន គឺត្រូវចំនាយពេលពី៥ ថ្ងៃ ទៅ ៦ ថ្ងៃទើបបញ្ចប់។ ប៉ុន្តែការងារ វាមិនទៀងទាត់នោះទេ ដែលធ្វើឲ្យមានការលំបាកក្នុងការចិញ្ចឹមបីបាច់សុធា និងបងប្អូនប្រាំនាក់ផ្សេងទៀត រួមនឹងបងប្រុសថ្លៃម្នាក់ទៀត ដែលអ្នកទាំងអស់រស់នៅក្នុងផ្ទះដ៏តូចមួយនៅក្នុងបរិវេណឡនោះ។

បន្ថែមពីការជួយការងារឪពុកម្តាយ នៅក្នុងឡឥដ្ឋ សុធា ជួយដឹកឥដ្ឋនៅក្នុងបរិវេណឡចូលក្នុងឡ និងយកចេញពីក្នុងឡមកវិញ បន្ទាប់ពីដុតឆ្អិនរួចមកដើម្បីឲ្យត្រជាក់។

សុធានិយាយថា៖ "មានការហត់នឿយ ពីព្រោះវាត្រូវការប្រើកំលាំងច្រើន"។

សុធា មិនបានទទួលប្រាក់ឈ្នួលទៀងទាត់ ពីម្ចាស់ឡនោះទេ។ សុធា ត្រឹមតែទទួលប្រាក់ជារៀងរាល់ថ្ងៃពីឪពុកម្តាយចំនួន ២,០០០ រៀល (០,៥ ដុល្លារសហរដ្ឋអាមេរិច) នៅពេលព្រឹក និង១,០០០ រៀល (០,២៥ ដុល្លារសហរដ្ឋអាមេរិច) នៅពេលថ្ងៃសម្រាប់ថ្ងៃទៅសាលាប៉ុណ្ណោះ។ ប្រសិនបើនៅសល់ប្រាក់ឪពុកម្តាយរបស់សុធានឹងឲ្យ១០,០០០រៀល (២,៥ ដុល្លារសហរដ្ឋអាមេរិច) នៃប្រាក់ឈ្នួលដែលអ្នកទាំងពីរទទួលបាន។

សុធា គឺជាក្មេងម្នាក់ក្នុងចំណោមក្មេងនៅក្នុងប្រទេសកម្ពុជា ដែលមានអាយុពី ៥ ដល់ ១៧ ឆ្នាំ ដែលមានចំនួនច្រើនគួរឲ្យកត់សម្គាល់ធ្វើការជាកម្មករឡឥដ្ឋ ហើយទទួលបានប្រាក់កំរៃ តិចតួចឬគ្មានទទួលបានអ្វីសោះ។យោងតាមរបាយការណ៍

ថ្មីៗនេះ ដែលត្រូវបានចេញផ្សាយដោយអង្គការពលកម្មអន្តរជាតិ (ILO) ១៩ ភាគរយ ក្នុងកុមារកម្ពុជាចំនួន ៤ លាននាក់ មានភាពសកម្មក្នុងការចេញទៅធ្វើពលកម្ម នៅឆ្នាំ២០១២។ នៅក្នុងចំណោមចំនួនកុមារខាងលើនេះ ១៧,៤ ភាគរយ ឬស្មើនឹង ៧៤,៦៥០ នាក់ ធ្វើការនៅក្នុងការិយាល័យ តូប ហាង និងមួយចំនួនទៀតធ្វើការក្នុងរោងចក្រ ដូចជាសុធាជាដើម។

កុមារដែលធ្វើការនៅក្នុងឡឥដ្ឋ គឺងាយរងគ្រោះជាពិសេស ព្រោះអ្នកទាំងនោះប្រឈមមុខនឹងកំដៅភ្លើង ធូលី និងផ្សែងពុល (ជាលក្ខខណ្ឌគ្រោះថ្នាក់ដែលអង្គការ ILO បានកំណត់)។ របាយការណ៍របស់អង្គការ ILO បានរាយការណ៍ថា នៅក្នុងឆ្នាំ ២០១២ មានត្រឹមតែ ២,៩ ភាគរយនៃកម្មករ ដែលជាកុមារប៉ុណ្ណោះ ធ្វើការនៅក្នុងលក្ខខណ្ឌគ្រោះថ្នាក់មួយចំនួន ដែលធ្វើឲ្យរឿងរបស់សុធា ជារឿងដែលចម្លែក និងមានតែមួយ។

តាមការប៉ាន់ស្មានរបស់សុធា មានក្មេងចំនួន ២០នាក់ រស់នៅកន្លែងធ្វើឥដ្ឋរបស់សុធា។ ក្នុងចំនោមអ្នកទាំងនោះមានចំនួន៨នាក់មិនបានទៅសិក្សារៀនសូត្រនោះទេ ផ្ទុយទៅវិញបែរជាការធ្វើការងារច្រើនរហូតដល់ទៅច្រើនជាង ៥ម៉ោងក្នុងមួយថ្ងៃ ដោយទទួលបានប្រាក់កម្រៃ ក្នុងមួយថ្ងៃ ១៦,០០០ រៀល (៤ ដុល្លារសហរដ្ឋអាមេរិក)។ ក្នុងចំនោមនោះ កុមារដែលក្មេងជាងគេ គឺមានអាយុ១២ឆ្នាំ។

ទោះបីជាមានការប្រឈមមុខជាមួយ នឹងឱកាសតិចតួច និងធនធានតិចតួច ក៏ដោយ ក៏សុធាបានប្តេជ្ញាចិត្តថានឹងធ្វើឲ្យជីវិតរបស់សុធា និងក្រុមគ្រួសាររបស់សុធាមានភាពប្រសើរឡើង។ សុធាបាននិយាយថា ជំហ៊ានដំបូងដែលសំខាន់ជាងគេ គឺរៀនសូត្រឲ្យបានពូកែ។

សុធា បានយល់ច្បាស់ពីរបៀបដែលធ្វើអោយខ្លួនប្រសើរឡើង គឺនៅ អំឡុងពេលដែលមានកិច្ចប្រជុំមួយ ស្តីអំពីក្រុមអ្នកការពារសិទ្ធិកុមារដែលបានរៀបចំឡើងដោយបុគ្គលិករបស់អង្គការ លីកាដូ នៅសាលារៀនរបស់សុធា កាលពីឆ្នាំ ២០១២។ ក្នុងកិច្ចប្រជុំនោះ សុធាបានយល់ច្បាស់ថា សុធាពិតជាមិនត្រូវធ្វើការនៅកន្លែងធ្វើឥដ្ឋពេញមួយជីវិតរបស់សុធានោះទេពីព្រោះការរៀនសូត្រធ្វើឲ្យមនុស្សមានជម្រើសច្រើន។

សុធាបាននិយាយថា" សុធាពូកែខាងគណិតវិទ្យា" ។ "ខ្ញុំចង់ក្លាយជាគណនេយ្យករម្នាក់។ប៉ុន្តែដើម្បីក្លាយជាគណនេ-យ្យករបាន ខ្ញុំត្រូវតែខិតខំប្រឹងប្រែងសិក្សារៀនសូត្រ និងស្វែងយល់ឲ្យបានច្រើនពីការងារនេះ"។

បច្ចុប្បន្ននេះ ដោយសារតែជាផ្នែកមួយនៃបណ្តាញក្រុមអ្នកការពារសិទ្ធិកុមាររបស់អង្គការលីកាដូ សុធា បានចូលរួមក្នុងការប្រជុំយ៉ាងតិចណាស់ម្តងក្នុងមួយខែ ដើម្បីជជែកពិភាក្សាអំពីសិទ្ធិកុមារ និងបញ្ហាពលកម្មលើកុមារជាមួយនឹងក្រុមកុមារ និងយុវជនមួយចំនួនទៀត ហើយព្រមទាំងបានលើកទឹកចិត្តដល់សហគមន៍សុធាក្នុងការបញ្ជូនកូនៗរបស់អ្នកទាំងនោះឲ្យទៅសាលារៀនទៀតផង។

សុធាបាននិយាយថា "ខ្ញុំបានចូលរួមដែរ ពីព្រោះខ្ញុំចង់


សុធា កំពុងដាក់ដីឥដ្ឋល្បាយខ្សាច់មុនពេលដែលចាប់ផ្តើមដុតឥដ្ឋក្នុងឡ

បង្ហាត់បង្រៀនដល់អ្នកធ្វើការជាមួយខ្ញុំ នៅឡឥដ្ឋឲ្យឈប់ធ្វើការជាកម្មករឡឥដ្ឋ ហើយឲ្យទៅសិក្សារៀនសូត្រវិញ"។ "ខ្ញុំចែករំលែកនូវចំនេះដឹងអំពីសិទ្ធិកុមារ រួមមានសិទ្ធិក្នុងការទទួលបានការរៀនសូត្រ និងសិទ្ធិក្នុងការធ្វើដំណើរទៅមកគ្រប់ទីកន្លែង"។

យោងតាមរបាយការណ៍ស្រាវជ្រាវ របស់អង្គការពលកម្មអន្តរជាតិ (ILO) ក្នុងឆ្នាំ២០១២ បានបញ្ជាក់ថាប្រហែលជា ១១ ភាគរយ នៃកុមារទូទាំងប្រទេសមិនបានចូលរៀននៅឆ្នាំ ២០១២។

សំណាងល្អដែល សុធា មិនដែលបានឃើញមានការរំលោភបំពានលើកុមារ នៅឡឥដ្ឋរបស់សុធានោះទេ។ ហើយនៅពេលដែលកម្មកររបស់រោងចក្របានរងរបួសម្ចាស់ឡឥដ្ឋ ក៏បានចំនាយប្រាក់ដើម្បីព្យាបាលទៀតផង។

សុធាបាននិយាយថា "ខ្ញុំមិនដែលបានឃើញមានការរំលោភបំពាននៅក្នុងឡឥដ្ឋរបស់ខ្ញុំទេ បន្តែខ្ញុំធ្លាប់បានឮទាក់ទងនឹងការរំលោភបំពានលើកុមារនៅឡឥដ្ឋដទៃទៀត ហើយជាកន្លែងដែលអ្នកចាត់ការនៅទីនោះ បានវាយដំលើស្រ្តីមានផ្ទៃពោះម្នាក់ទៀតផង"។

ទោះបីជាមានទំនាក់ទំនងល្អជាមួយនឹងម្ចាស់ឡូតដ្ឋក៏ដោយ សុធា នៅតែមានការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់ក្រុមគ្រួសាររបស់សុធា។ អ្នកទាំងនោះមិនមានបណ្តាញក្នុងការទំនុកបំរុងឲ្យបានរឹងមាំនោះទេ ហើយផ្ទះម្តាយឪពុកសុធានៅឯខេត្តស្វាយរៀងដែលមានចំងាយរាប់រយគីឡូម៉ែត្រនៅភាគខាងត្បូងប្រទេសឯនោះ។

សុធា បាននិយាយថា "ប្រសិនបើមានអ្វីមិនល្អកើតឡើងចំពោះក្រុមគ្រួសាររបស់សុធា គឺគ្មាននរណាម្នាក់អាចជួយបានឡើយ"។

ម្យ៉ាងវិញទៀត ម្តាយឪពុករបស់សុធាមិនបានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយនឹងថៅកែឡូតដ្ឋនោះទេ ហើយអ្នកទាំងពីរអាចប្រឈមមុខនឹងការបាត់បង់ការងារ ប្រសិនបើរងគ្រោះថ្នាក់ ឬក៏ដោយសារភាពចាស់ជរារបស់អ្នកទាំងពីរ។ នេះហើយជាមូលហេតុ ដែលពួកគាត់ត្រលប់ទៅកាន់ខេត្តស្វាយរៀងវិញដើម្បីធ្វើស្រែចំការ ឬធ្វើការនៅឧស្សាហកម្មកាត់ដេរ ដែលចំណាយកម្លាំងតិច។

សំខាន់បំផុត សុធា ព្រួយបារម្ភថា ប្រសិនបើក្រុមគ្រួសាររបស់សុធាស្នាក់នៅឡូតដ្ឋ ថវិកាដែលអ្នកទាំងនោះរកបាន គឺមិនគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ដល់សុធាក្នុងការបញ្ចប់ការសិក្សា ដើម្បីឲ្យក្លាយជាគណនេយ្យករបានទេ។

សុធាបាននិយាយថា "ខ្ញុំមិនថវិកាគ្រប់គ្រាន់ដើម្បីទៅរៀនសូត្របានឡើយ ព្រោះម្តាយឪពុករបស់ខ្ញុំមិនមានថវិកាគ្រប់គ្រាន់ក្នុងការបញ្ជូនខ្ញុំទៅសាលារៀនបានទេ"។

សម្រាប់សុធា ការតស៊ូមតិដើម្បីអោយកុមារទទួលបានការសិក្សា គឺជារឿងសំខាន់របស់សុធា។ សុធាយល់ថា ការសិក្សារៀនសូត្រ គឺជាស្ពានដើម្បីធ្វើឲ្យជីវិតល្អប្រសើរ ហើយជាជីវិតមួយក្នុងក្តីស្រមៃរបស់គាត់នាពេលបច្ចុប្បន្ននេះ។ អំឡុងពេលដែលសុធាចូលសាលា សុធាបានលេងបាល់ទាត់ជាមួយមិត្តភិក្ត ហើយព្រមទាំងបានជួយធ្វើការងារម្តាយឪពុកនៅផ្ទះ និងកន្លែងធ្វើការទៀតផង។

សុធាបានបន្តថា "ខ្ញុំគិតថាក្មេងៗមិនគួរធ្វើការនៅឡូតដ្ឋនោះទេ"។ "ពួកគេគួរតែទៅសិក្សារៀនសូត្រវិញ ពីព្រោះប្រសិនបើអ្នកទាំងនោះធ្វើការនៅឡូតដ្ឋនោះ ពួកគេនឹងធ្វើការនៅទីនោះពេញមួយជីវិតរបស់អ្នកទាំងនោះ"។

ដើម្បីចូលទៅកាន់របាយការណ៍ របស់អង្គការពលកម្មអន្តរជាតិ (ILO) ស្តីពី "ការស្ទាបស្ទង់មតិអំពីពលកម្មកុមារ និងកម្លាំងពលកម្មនៅកម្ពុជា ឆ្នាំ២០១២៖ របាយការណ៍ស្តីពីពលកម្មកុមារ ឆ្នាំ២០១៣" សូមចូលទៅកាន់៖ http://bit.ly/JzrlVD